**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ០០៤ សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥

# សារាចរណែនាំ

## ស្តីពី

## យន្តការបង្វិលសងប្រាក់អាករលើតម្លៃបន្ថែម

អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ បទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែមលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ និងបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីវិសោធនកម្មនៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែមលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ សំដៅធានាដល់ការបង្វិលសងប្រាក់អាករលើតម្លៃបន្ថែមឱ្យបានសមស្របនិងទៀងទាត់ យន្តការនៃការបង្វិលសងប្រាក់អាករលើតម្លៃបន្ថែមត្រូវអនុវត្តដូចខាងក្រោមនេះ :

**១ - លក្ខខណ្ឌនៃការបង្វិលសង**

យោងតាម មាត្រា ៧២ និងមាត្រា ៧៣ នៃច្បាប់ស្តីពីសារពើពន្ធ មាត្រា ៤០ និងមាត្រា ៤១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម សហគ្រាសដែលមានសិទ្ធិស្នើសុំបង្វិលសងប្រាក់អតបត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

ក- មានឥណទានអាករលើធាតុចូលលើសប្រចាំខែ ចំពោះបុគ្គលជាប់អាករដែលមានការនាំចេញជាសំខាន់ ឬបានចុះបញ្ជីសហគ្រាសវិនិយោគ ។

ខ- មានឥណទានអាករលើធាតុចូលលើសចាប់ពី ៣ ខែ ជាប់គ្នាឡើងទៅ ចំពោះបុគ្គលជាប់អាករដទៃទៀត ។

គ- មានភស្តុតាងនៃការបង់ប្រាក់អាករលើធាតុចូល រួមមានប្រតិវេទន៍គយសម្រាប់ការនាំចូលព្រមទាំងបង្កាន់ដៃដើមនៃបង្កាន់ដៃគយដែលបញ្ជាក់ពីការបង់ប្រាក់អាករដែលអាចអនុញ្ញាតជាឥណទាន ឬច្បាប់ដើមនៃវិក្កយបត្រអាករចេញដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក ។

ឃ- មានភស្តុតាងនៃការនាំចេញដែលត្រូវជាប់អាករតាមអត្រាសូន្យ ។

ង- មានបញ្ជីកាគណនេយ្យអាករលើតម្លៃបន្ថែមដែលអាចជឿទុកចិត្តបាន រួមមាន ទិនានុប្បវត្តិ ទិញ លក់ ព្រមទាំងកំណត់ត្រាជំនួយផ្សេងៗ ។

**២ - វិធានសម្រាប់កំណត់លក្ខណៈសម្បត្តិរបស់សហគ្រាសដើម្បីចុះធ្វើសវនកម្ម**

ផ្អែកតាមប្រវត្តិនៃការគោរពប្រតិបត្តិរបស់សហគ្រាសចំពោះច្បាប់ស្តីពីសារពើពន្ធ នាយកដ្ឋានពន្ធដារត្រូវធ្វើការបែងចែកសហគ្រាសដែលបានស្នើសុំបង្វិលសងជាបីប្រភេទដូចខាងក្រោម :

ក- ប្រភេទ **"មាស"**

ប្រភេទមាស គឺជាសហគ្រាសដែលមានប្រវត្តិសារពើពន្ធល្អក្នុងរយៈពេល ០៣ ឆ្នាំជាប់គ្នា កន្លងមក ។ សហគ្រាសប្រភេទនេះមានលក្ខណៈសម្បត្តិដូចតទៅ :

- កាន់កាប់កត់ត្រាបញ្ជីកាគណនេយ្យបានត្រឹមត្រូវក្នុងរយៈពេល ០៣ ឆ្នាំ កន្លងមក
- មានសកម្មភាពផ្គត់ផ្គង់ទំនិញឬសេវាជាប្រចាំ
- គ្មានកំហុសឆ្គង ឬភស្តុតាងថាបានបន្លំប្រាក់ពន្ធ ឬស្នើសុំបង្វិលសងលើស
- មានប្រវត្តិនៃការប្រកាសនិងបង់ពន្ធទាន់ពេលវេលានិងទៀងទាត់
- មានការបញ្ជាក់ពីធនាគារអំពីស្ថានភាពល្អប្រសើរនៃគណនីរបស់សហគ្រាស
- បញ្ជីគណនេយ្យនិងកំណត់ត្រានានា ត្រូវបានធ្វើសវនកម្មសារពើពន្ធ យ៉ាងតិច ០៦ រយៈពេលជាប់អាករ ក្នុងរយៈពេល ២៤ ខែ កន្លងមក
- គ្មានការកំណត់ពន្ធឡើងវិញណាមួយដែលមានទឹកប្រាក់លើសពី ១០% នៃប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ បានធ្វើឡើងក្នុងរយៈពេលធ្វើសវនកម្មកន្លងមក ។

សម្រាប់សហគ្រាសប្រភេទ "មាស" ការស្នើសុំបង្វិលសងដែលមានទឹកប្រាក់តិចជាង ២០ លានរៀល មិនតម្រូវឱ្យមានការធ្វើសវនកម្មដល់ទីកន្លែង និងមិនត្រូវបានតម្រូវឱ្យដាក់ឯកសារជំនួយជាមួយនិងពាក្យស្នើសុំបង្វិលសងឡើយ ហើយការស្នើសុំបង្វិលសងត្រូវបានអនុញ្ញាតក្នុងរយៈពេល ២៧ ថ្ងៃ នៃថ្ងៃធ្វើការ ។ ការធ្វើសវនកម្មជាក្រោយ ត្រូវបានធ្វើឡើងយ៉ាងហោចណាស់ទៅលើការស្នើសុំពីរឬបី នៃការស្នើសុំនានាដែលបានធ្វើឡើងក្នុងរយៈពេល ១២ ខែ កន្លងមក ។ សម្រាប់ការស្នើសុំបង្វិលសងដែលមានទឹកប្រាក់ចាប់ពី ២០ លានរៀលឡើងទៅ តម្រូវឱ្យមានការធ្វើសវនកម្មដល់ទីកន្លែងជាធម្មតា ហើយការស្នើសុំបង្វិលសងត្រូវបានអនុញ្ញាតក្នុងរយៈពេលយ៉ាងយឺត ៣២ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យដាក់ពាក្យស្នើសុំបង្វិលសង ។ ក្នុងករណីដែលភាពមិនត្រឹមត្រូវកើតមានឡើងលក្ខណៈសម្បត្តិ "មាស" ត្រូវបានដកហូត ។

ខ- <u>ប្រភេទ **"ប្រាក់"**</u>

ប្រភេទប្រាក់ គឺជាសហគ្រាសដែលមានប្រវត្តិសារពើពន្ធល្អក្នុងរយៈពេល ០១ ឆ្នាំ កន្លងមក ។ សហគ្រាសប្រភេទនេះមានលក្ខណៈសម្បត្តិដូចតទៅ :

- កាន់កាប់កត់ត្រាបញ្ជីកាគណនេយ្យបានត្រឹមត្រូវក្នុងរយៈពេល ០១ ឆ្នាំ កន្លងមក យ៉ាងតិច
- មានសកម្មភាពផ្គត់ផ្គង់ទំនិញឬសេវាជាប្រចាំ
- មានប្រវត្តិនៃការប្រកាសនិងបង់ពន្ធទាន់ពេលវេលានិងទៀងទាត់
- គ្មានភស្តុតាងបញ្ជាក់ពីការបន្លំស្នើសុំបង្វិលសង
- បញ្ជីគណនេយ្យនិងកំណត់ត្រានានា ត្រូវបានធ្វើសវនកម្មសារពើពន្ធ យ៉ាងតិច ០៣ រយៈពេលជាប់អាករ ក្នុងរយៈពេល ២៤ ខែ កន្លងមក ។

សម្រាប់សហគ្រាសប្រភេទ "ប្រាក់" ការស្នើសុំបង្វិលសងដែលមានទឹកប្រាក់តិចជាង ០៥ លានរៀល មិនតម្រូវឱ្យមានការធ្វើសវនកម្មដល់ទីកន្លែងឡើយ តែតម្រូវឱ្យភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនូវឯកសារនានាដែលបញ្ជាក់ពីការបង់ប្រាក់អាករលើតម្លៃបន្ថែម ហើយការស្នើសុំបង្វិលសងត្រូវបានអនុញ្ញាតក្នុងរយៈពេលយ៉ាងយឺត ៣២ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការធ្វើសវនកម្មយ៉ាងសង្ខេបទៅលើឯកសារដែលបានភ្ជាប់មកជាមួយនោះ ។ សម្រាប់ការស្នើសុំបង្វិលសងដែលមានទឹកប្រាក់ចាប់ពី ០៥ លានរៀល ឡើងទៅ តម្រូវឱ្យមានការធ្វើសវនកម្មដល់ទីកន្លែងជាធម្មតា ហើយការស្នើសុំបង្វិលសងត្រូវបានអនុញ្ញាតក្នុងរយៈពេលយ៉ាងយឺត ៣៦ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យដាក់ពាក្យស្នើសុំបង្វិលសង ។ ក្នុងករណីដែលភាពមិនត្រឹមត្រូវកើតមានឡើងលក្ខណៈសម្បត្តិ "ប្រាក់" ត្រូវបានដកហូត ។

គ- <u>ប្រភេទ **"ធម្មតា"**</u>

ប្រភេទ "ធម្មតា" គឺសហគ្រាសក្រៅពីសហគ្រាសប្រភេទ "មាស" និងប្រភេទ "ប្រាក់" ។

សម្រាប់សហគ្រាសប្រភេទ "ធម្មតា" រាល់ការស្នើសុំបង្វិលសងតម្រូវឱ្យមានការធ្វើសវនកម្មដល់ទីកន្លែង ហើយការស្នើសុំបង្វិលសងត្រូវបានអនុញ្ញាតក្នុងរយៈពេល ៣៨ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យដាក់ពាក្យស្នើសុំបង្វិលសង ។

**៣ - <u>ប្រព័ន្ធទាត់ចែងឯកសារស្នើសុំបង្វិលសង</u>**

ដើម្បីធានាឱ្យការបង្វិលសងប្រព្រឹត្តទៅបានឆាប់រហ័ស ការធ្វើសវនកម្មនិងការចាត់ចែងឯកសារត្រូវអនុវត្តឱ្យបានត្រឹមត្រូវហ្មត់ចត់ទៅតាមនីតិវិធីសម្រាប់ចាត់ចែងការបង្វិលសងដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់នឹងសារាចរនេះ ។ សហគ្រាសដែលជាអ្នកស្នើសុំបង្វិលសងត្រូវផ្តល់ឯកសារ និងបញ្ជីកានានា ដូចមានចែងក្នុងចំណុច១ ខាងលើ ឱ្យបានគ្រប់គ្រាន់និងតាមពេលវេលាកំណត់របស់នាយកដ្ឋានពន្ធដារ ពុំនោះទេការស្នើសុំបង្វិលសងត្រូវបានព្យួរទុករហូតដល់ថ្ងៃដែលនាយកដ្ឋានពន្ធដារបានទទួលឯកសារនិងបញ្ជីកាទាំងនោះ ។

ចំពោះការចាត់ចែងការបង្វិលសងដល់ បេសកកម្មការទូត អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលនានា ត្រូវអនុវត្តទៅតាមរយៈពេលនៃដំណាក់នីមួយៗនៃសហគ្រាសប្រភេទ "មាស" ។

**ឧសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឧបសម្ព័ន្ធភ្ជាប់នឹងសារាចរណែនាំស្តីពីយន្តការបង្វិលសងប្រាក់អាករលើតម្លៃបន្ថែម លេខ ......០០៤...... ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៥

| ការងារមាត់ចែង | ប្រភេទ មាស | | ប្រភេទ ធ្លាក់ | | ប្រភេទ ធម្មតា |
|---|---|---|---|---|---|
| | តិចជាង២០លានរៀល | ចាប់ពី២០លានរៀលឡើងទៅ | តិចជាង៥០លានរៀល | ចាប់ពី៥០លានរៀលឡើងទៅ | |
| សរុបចំនួនថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំបង្វិលសងសម្រាប់ខែនីមួយៗ | ២៧ ថ្ងៃ | ៣២ ថ្ងៃ | ៣២ ថ្ងៃ | ៣៦ ថ្ងៃ | ៣៨ ថ្ងៃ |
| ស្រង់ឈ្មោះសហគ្រាសចេញពីកំណត់ត្រារបស់ក្រុមចាត់ចែងលិខិតប្រកាស ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ |
| ផ្នែកសវនកម្ម រៀបចំមន្ត្រីចុះធ្វើសវនកម្ម លើការស្នើសុំបង្វិលសងតាមវិធាន ដូចមានចែងក្នុងចំណុច ២ ។ | | ០៦ ថ្ងៃ | | ០៦ ថ្ងៃ | ០៨ ថ្ងៃ |
| ផ្នែកសវនកម្ម ធ្វើរបាយការណ៍ស្តីពីការចុះធ្វើសវនកម្មការស្នើសុំបង្វិលសង (ទម្រង់អតប ៣០៣ ខ) ហើយប្រធានផ្នែកត្រូវពិនិត្យផ្តល់មតិដោយផ្អែកលើលក្ខខណ្ឌទាំងអស់នៅក្នុងចំណុច ១ ខាងលើ ។ | ០៥ ថ្ងៃ | ០៤ ថ្ងៃ | ០៥ ថ្ងៃ | ០៤ ថ្ងៃ | ០៤ ថ្ងៃ |
| ប្រធានអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ.មធ្យម ពិនិត្យនិងផ្តល់មតិលើរបាយការណ៍សវនកម្ម និងរៀបចំលិខិតសុំសេចក្តីសម្រេច (ទម្រង់អតប២២៧) បញ្ជូនទៅប្រធានការិយាល័យរបបពិត ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ |
| ប្រធានការិយាល័យរបបពិតផ្តល់មតិលើរបាយការណ៍បញ្ជូនទៅលោកអនុប្រធាននាយកដ្ឋានពន្ធដារទទួលបន្ទុក ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ |
| លោកអនុប្រធាននាយកដ្ឋានពន្ធដារទទួលបន្ទុក ពិនិត្យ និងផ្តល់មតិលើរបាយការណ៍ ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ |
| លោកប្រធាននាយកដ្ឋានពន្ធដារ ចុះហត្ថលេខាលើលិខិតសុំសេចក្តីសម្រេច (ទម្រង់អតប២២៧) បញ្ជូនទៅនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ |
| នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ រៀបចំអាណត្តិបើកប្រាក់បញ្ជូនទៅអគ្គនាយកហិរញ្ញវត្ថុ ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ |
| អគ្គនាយកហិរញ្ញវត្ថុចុះហត្ថលេខាលើអាណត្តិបើកប្រាក់ រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចលើការស្នើសុំបង្វិលសង និងចុះហត្ថលេខាលើអាណត្តិបើកប្រាក់ ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ |
| អាណត្តិបើកប្រាក់ត្រូវបានបញ្ជូនមកនាយកដ្ឋានពន្ធដារវិញដើម្បីកត់ត្រាតាមដានការវិវឌ្ឍន៍នៃការស្នើសុំបង្វិលសង។ | ០១ ថ្ងៃ | ០១ ថ្ងៃ | ០១ ថ្ងៃ | ០១ ថ្ងៃ | ០១ ថ្ងៃ |
| អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ.មធ្យម រៀបចំ (ទម្រង់អតប២២៨) ជូនដំណឹងអំពីការអនុញ្ញាតិបង្វិលសងផ្ញើជូនសហគ្រាស និងបញ្ជូនអាណត្តិបើកប្រាក់ទៅធនាគារជាតិ ដើម្បីធ្វើការទូទាត់បង្វិលសង ។ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ | ០២ ថ្ងៃ |
| ការទូទាត់ប្រាក់បង្វិលសងនៅធនាគារជាតិ ។ ក្រោយការទូទាត់ ច្បាប់ចម្លងនៃឯកសារទូទាត់ត្រូវបានបញ្ជូនមកអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ.មធ្យម ដើម្បីកត់ត្រាតាមដានបញ្ចប់នីតិវិធីបង្វិលសង ។ | ០៣ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ | ០៣ ថ្ងៃ |

បញ្ជាក់ : ១. សម្រាប់ការចាត់ចែងឯកសារស្នើសុំបង្វិលសងដែលធ្វើឡើងដោយផ្នែករបបពិតតាមសាខាពន្ធដារខេត្ត/ក្រុងនានាត្រូវបានបន្ថែមចំនួន ០៧ ថ្ងៃទៀត ។

២. ចំនួនថ្ងៃមានន័យជាចំនួនថ្ងៃធ្វើការ ។